បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 30 ខែ 04 ឆ្នាំ 2003

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៩-៣-២០០០ - ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១៣៥ តែងតាំង និងបំពាក់ឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយត្រី ជូននាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ៥៥០

៣១-៣-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០៣០០/០៥២ តំលើងឋានៈឯកឧត្តម ហ៊ុយ ពិសិដ្ឋ ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ៥៥១

៣១-៣-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០៣០០/០៥២ តំឡើងឋានៈជូនឯកឧត្តម ហ៊ិង ប៊ុនហៀង ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ៥៥២

## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

២៩-៣-២០០០ - អនុក្រឹត្យ លេខ ១៤ អនក្រ.បក ស្តីពីការកែសំរួលឯកសណ្ឋាន និងផ្លាកសញ្ញា របស់នគរបាលជាតិកម្ពុជា ៥៥៣

២៧-៣-២០០០ - អនុក្រឹត្យ លេខ ១១៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥៦២

២៧-៣-២០០០ - អនុក្រឹត្យ លេខ ១១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៦៣

២៧-៣-២០០០ -អនុក្រឹត្យ លេខ ១២០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៦៤

២៨-៣-២០០០ -អនុក្រឹត្យ លេខ ១២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦៥

២៨-៣-២០០០ -អនុក្រឹត្យ លេខ ១២២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៦៦

២៨-៣-២០០០ -អនុក្រឹត្យ លេខ ១២៣ អនក្រ.តត ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ ៥៦៧

២៨-៣-២០០០ -អនុក្រឹត្យ លេខ ១២៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៦៨

២៩-៣-២០០០ -អនុក្រឹត្យ លេខ ១២៥ អនក្រ.តត ស្តីពីការជូនមេដាយ សុវត្ថារា ៥៦៩

### ២-សេចក្តីសំរេច

៣១-៣-២០០០ -សេចក្តីសំរេច លេខ ១៧ សសរ ស្តីពីការបង្កើតក្រុមពិគ្រោះយោបល់ដំបូង សមុទ្រថៃ ខាងភាគីកម្ពុជា និងជាក្រុមពិគ្រោះយោបល់ថ្នាក់ជាតិ ៥៧១

## III- ការងារបណ្ដាក្រសួង

### -ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

#### ប្រកាស

២៧-៣-២០០០ - ប្រកាស លេខ ២១៣ បល.ប្រក ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ នាយកដ្ឋានឧស្សាហកម្មតូច សិប្បកម្ម ៥៧៣

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៣០០/១៣៥

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្ត ណោះរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់អនុក្រឹត្យលេខ ៣៧/អនក្រ/តត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង នៃក្រសួងការពារជាតិ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

#### ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំង និងបំពាក់ឋានន្តរសក្តិនាយទាហានជាន់ខ្ពស់ ថ្នាក់ឧត្តមសេនីយ៍ត្រី ក្នុងកងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម ៖

១- លោក សូ ហុង ទីប្រឹក្សាក្រសួងការពារជាតិ

២- លោក ឌុល សារឿន ទីប្រឹក្សាក្រសួងការពារជាតិ

៣- លោក សាំង គង់ ទីប្រឹក្សាក្រសួងការពារជាតិ

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

**ព្រះរាជក្រឹត្យ នស/រកត/០៣០០/០៥២**

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់អនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់សំណើនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបានតម្លើងឋានៈជូនឯកឧត្តម ហ៊ុយ ពិសិដ្ឋ នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

**ព្រះរាជក្រឹត្យ នស/រកត/០៣០០/០៥៣**

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់ទតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់អនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់សំណើនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០០០

ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបានតម្លើងឋានៈជូនឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៨/អនក្រ.បក

### ស្តីពីការកែសំរួលឯកសណ្ឋាន និងផ្លាកសញ្ញា របស់នគរបាលជាតិកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៣៩៨/០៩៣ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីរូបភាព លំដាប់សក្តិរបស់កងកម្លាំងនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ០៩/អនក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញារបស់នគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

មាត្រា ១ ._ ឯកសណ្ឋាននគរបាលជាតិកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម :

១- រូបភាព និងខ្នាតឯកសណ្ឋាន :

ក- ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ : មាន ០៧ ប្រភេទគឺ :

ក/១- ឯកសណ្ឋានធំលេខ ១ : "កុដស"

១- ឯកសណ្ឋានធំលេខ ១ អាវកុដស សំរាប់ប្រើប្រាស់ក្នុងព្រះរាជពិធីផ្សេងៗ ។

២- រូបភាព និងម៉ូត :

- អាវកុដស : ក ត្រង់ដៃវែង កាត់រាងអាវធំ មានប៊ូតុងស្លា និងគ្មានផែកខ្នង ។

ចុងក អាវទាំងសងខាងមានឡាត់រាងក្ដួរត្រូវពណ៌មាស បណ្ដោយប្រវែង ៥ ស.ម ទទឹង៣ ស.ម ។ អាវនេះមានហោប៉ៅចំនួនបួនគឺ ហោប៉ៅខាងលើមានពីរ (ហោប៉ៅប៉ះ) គូហោប៉ៅមួយកណ្ដាល ហោប៉ៅមានផ្លិបផ្ទត់មួយ គំរបហោប៉ៅរាងចតុកោណកែង តែចុងគំរបសងខាងនិងកណ្ដាលរាងស្រួច លើមានឡេវរូបព្រះសង្ហារពណ៌មាស ។

- ហោប៉ៅខាងក្រោមមានពីរ (ហោប៉ៅកាត់) គំរបហោប៉ៅរាងចតុកោណកែង ត្រង់ពីរខាងក្រោមរាងមូល ។

- ពីចុងដៃអាវប្រវែង ៦.៥ ស.ម មានប៉ាក់ក្រណាត់ពណ៌មាសព័ទ្ធជុំវិញដៃអាវ និងមានឡេវរូបព្រះសង្ហារពណ៌មាសចំនួន បីគ្រាប់ដាក់បញ្ឈូត ។

- ខោ : ជើងវែងពណ៌ខ្មៅ ចង្កេះត និងគ្មានភ្លី ។ ហោប៉ៅខោមានចំនួនបីគឺ ហោប៉ៅខាងក្រោយមានចំនួនមួយ (ហោប៉ៅកាត់) គ្មានគំរប ចោះរន្ធដាក់ឡេវមួយគ្រាប់ ហោប៉ៅចំហៀងសងខាងមានចំនួនពីរដេរបង្កប់តាមថ្នេរខោ ពីថ្នេរចង្កេះខោរហូតដល់ចុងជើងខោទាំងសងខាងមានប៉ាន់ធ្នូតពីរពណ៌បៃតង ប៉ាន់នីមួយៗមានទទឹងប្រវែង ១.៥ ស.ម ។

- មួកតាស្គេតធ្វើអំពី ក្រណាត់ពណ៌ខ្មៅ ។ ជើងមួកផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសចំនួនពីរគ្រាប់ ។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង ។ នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ១។

- ពាក់ខ្សែឥស្សរិយយសពណ៌មាស នៅលើស្មាខាងស្ដាំ ។

- ពាក់ស្រោមដៃពណ៌ស ។

- ក្រវាត់ខ្សែក្រវាត់ធំពណ៌មាស ពីលើអាវសំរាប់ព្យួរដាវខាងឆ្វេង ។

- ស្បែកជើងកខ្លី ពណ៌ខ្មៅ ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

ក/២- ឯកសណ្ឋានធំលេខ ២ : "ភារីពណ៌ខៀវចាស់" :

១- ឯកសណ្ឋានធំលេខ ២ ភារីពណ៌ខៀវចាស់ សំរាប់ប្រើប្រាស់ក្នុងពិធីបុណ្យជាតិពិធីផ្លូវការ ទទួលភ្ញៀវអន្តរជាតិ និងបំពេញបេសកកម្មនៅក្រៅប្រទេស ។

២- រូបភាព និងម៉ូត :

- អាវភារី : ដៃវែង កបើក ប៉ូលស្មា និងឆែកខ្នង ។

អាវនេះមានហោប៉ៅចំនួនបួន : ហោប៉ៅខាងលើមានចំនួនពីរ (ហោប៉ៅប៉ះ) ចំកណ្តាលមានជីបផ្នត់មួយ និងហោប៉ៅខាងក្រោមមានចំនួនពីរ (ហោប៉ៅកាត់) ហោប៉ៅទាំងបួនមានគំរបរាងចតុកោណកែង តែចុងគំរបសងខាង និងកណ្តាលរាងស្រួច អាវនេះមានឡេវរូបព្រះសង្ហារពណ៌មាសចំនួនបួនគ្រាប់ នៅចុងដៃអាវម្ខាងៗមានឡេវរូបព្រះសង្ហារពណ៌មាសចំនួនបីគ្រាប់ដាក់បញ្ឈោត ។

- ខោ : ជើងវែង ថ្នេរបង្កប់ ចង្កេះត និង គ្មានភ្លី ។

- ហោប៉ៅមានចំនួនបី : ហោប៉ៅខាងក្រោយមានចំនួនមួយ ដេរបង្កប់គ្មានគំរប និងហោប៉ៅចំហៀងទាំងសងខាង ដេរបង្កប់តាមថ្នេរខោ ។

- មួកកាស្កេតធ្វើអំពីក្រណាត់ពណ៌ខៀវចាស់ ឯរូបភាព និងម៉ូតដូចមួកកាស្កេតក្នុងឯកសណ្ឋានធំលេខ ១ ។

- អាវ : សឺមី កខុប ដៃវែងពណ៌ផ្ទៃមេឃពាក់ខាងក្នុង ។ អាវនេះមានហោប៉ៅមួយគ្មានគំរប កាត់ស្រុងដាក់ក្នុងខោ ។

- ក្រវាត់កពណ៌ខៀវចាស់ មេក្រវាត់ក មានរូបសញ្ញានគររាជជាតិប្រភេទ ៩ ពណ៌មាសនៅចំកណ្តាល ។

- ពាក់ខ្សែឥស្សរិយយសពណ៌មាសនៅលើស្មាខាងស្តាំ ។

- ពាក់ស្រោមដៃពណ៌ស ។

- ស្បែកជើងកខ្លីពណ៌ខ្មៅ ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

ក/៣- ឯកសណ្ឋានធំលេខ ៣ : "ស្តិនស័រ" :

១- ឯកសណ្ឋានធំលេខ ៣ ស្តិនស័រ សំរាប់ប្រើប្រាស់ក្នុងពិធីសមោសរ និងពិធីជប់លៀង ។

២- រូបភាព និងម៉ូត :

- អាវ : ស្តិនស័រ ដៃវែង ពណ៌ស ប៉ូលស្មា និងកាត់ខើចត្រឹមចង្កេះ ។

អាវនេះមានឡេវម្ខាងៗចំនួនបីគ្រាប់ដាក់បញ្ឈោតខាងមុខ ។ នៅចុងដៃអាវម្ខាងៗមានឡេវរូបព្រះសង្ហារពណ៌មាសចំនួនបីគ្រាប់ដាក់បញ្ឈោត ។

- ខោ : ដូចឯកសណ្ឋានធំលេខ ១ ។

- អាវ : សឺមីកខុប ដៃវែង ពណ៌សពាក់ពីក្នុង ។ ផ្នែកខាងមុខអាវនេះ មានថ្នេរផ្នត់តូចៗពេញផ្ទៃខាងមុខអាវ ។
- ពាក់ណិតពណ៌ខ្មៅ ។
- ពាក់មួកកាស្កេតដូចឯកសណ្ឋានធំលេខ ១ ។

ក/៤- ឯកសណ្ឋានការងារលេខ ៤ : "សាហារីយ៉ែន" :

១- ឯកសណ្ឋានការងារលេខ ៤ សាហារីយ៉ែន សំរាប់ប្រើប្រាស់ក្នុងពិធីមិទ្ទិញ សិក្ខាសាលា ទទួលភ្ញៀវជាតិ ប្រជុំការងារ និងបំពេញការងារប្រចាំថ្ងៃ ។

២- រូបភាព និងម៉ូត :

- អាវសាហារីយ៉ែននេះ : ដៃខ្លី កបើក ពណ៌កាគី កាត់រាងអាវធំ ប៉ូលស្នា និងឆែកខ្នង ។ អាវនេះមានហោប៉ៅចំនួនបួន : ហោប៉ៅខាងលើមានចំនួនពីរ (ដេរប៉ះ) នៅចំកណ្តាលមានបត់ផ្នត់មួយ និងហោប៉ៅខាងក្រោមមានចំនួនពីរ (ដេរប៉ះ) ចំកណ្តាលបត់ផ្នត់មួយ ។ គំរបហោប៉ៅទាំងបួនរាងចតុកោណកែង តែចុងគំរបសងខាង និងកណ្តាលរាងស្រួច ឡេវអាវរូបព្រះលញ្ឆករពណ៌មាស ។
- ខោ : ជើងវែងពណ៌កាគី ថ្នេរបង្កប់ ចង្កេះគ និងគ្មានភ្លី ។
- ហោប៉ៅខោមានចំនួនបួន : ហោប៉ៅក្រោយមានចំនួនពីរ ដេរបង្កប់គ្មានគំរប ចោះរន្ធដាក់ឡេវចំនួនមួយគ្រាប់ និងហោប៉ៅចំហៀងសងខាងដេរបង្កប់តាមថ្នេរខោ ។
- ពាក់មួកកាស្កេតដូចឯកសណ្ឋានធំលេខ ២ ឬមួកហ្សិកគីពណ៌ខៀវចាស់ ។
- ស្បែកជើងកន្លឹ គរខ្សែពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ ។

ក/៥. ឯកសណ្ឋានការងារលេខ ៥ :

១- ឯកសណ្ឋានការងារលេខ៥ សំរាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ ។

២- រូបភាព និងម៉ូត :

- អាវពណ៌កាគី : កខុប ប៉ូលស្នា និងដៃខ្លី ។

អាវនេះកាត់ស្រួង ជើងអាវញៀលដាក់ក្នុងខោ មានហោប៉ៅខាងលើចំនួនពីរ (ដេរប៉ះ) នៅចំកណ្តាលបត់ផ្នត់មួយ ។ គំរបហោប៉ៅមានរាងស្លឹកពោធិ៍ ។ ឡេវអាវពណ៌កាគី ។

- ខោ : ដូចឯកសណ្ឋានការងារលេខ៤ ។
- ពាក់ខ្សែក្រវាត់តូចពណ៌ខ្មៅ ។ ក្បាលខ្សែក្រវាត់នេះមានរូបកម្រងកួរស្រូវអមលំអទ្រូវ រូបរាជសីហ៍ពណ៌មាសរាងជាស្នែងក្របី ។
- ស្បែកជើង ស្រោមជើង និងខ្សែក្រវាត់ដូចឯកសណ្ឋានធំលេខ ២ ។

- មួកកាស្កេត ដូចឯកសណ្ឋានធំលេខ ២ ឬមួកហ្សេកកីពណ៌ខៀវចាស់ ។

ក-៦- ឯកសណ្ឋានការងារលេខ ៦ :

១- ឯកសណ្ឋានការងារលេខ ៦ សំរាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ ។

២- រូបភាព និងម៉ូត :

-អាវដៃវែងពណ៌កាគី : កខុប ប៉ូលេស្មា និងចុងដៃអាវខុប ។

អាវនេះកាត់ស្រុង ជើងអាវវៀល ដាក់ក្នុងខោ ។ អាវនេះមានហោប៉ៅចំនួនពីរ (ដេរប៉ះ) នៅចំកណ្តាលបត់ផ្នត់មួយ គំរបហោប៉ៅអាវមានរាងស្លឹកពោធិ៍ ។ ឡេវអាវពណ៌កាគី ។

-ខោ ស្បែកជើង ស្រោមជើង និងខ្សែក្រវ៉ាត់ ដូចឯកសណ្ឋានការងារលេខ ៥ ។

-មួកកាស្កេត ឬមួកហ្សេកកី ដូចឯកសណ្ឋានការងារលេខ ៥ ។

ក-៧- ឯកសណ្ឋានការងារលេខ ៧ :

១- ឯកសណ្ឋានការងារលេខ ៧ ពណ៌បៃតងចាស់ សំរាប់ប្រើប្រាស់ក្នុងអង្គភាពប្រតិបត្តិការមួយចំនួន ដែលកំណត់តាមប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

២- រូបភាព និងម៉ូត :

-អាវនេះមានរូបភាព និងម៉ូតដូចឯកសណ្ឋានប្រតិបត្តិការរបស់កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ។

អាវនេះមានហោប៉ៅចំនួនបួន : ហោប៉ៅខាងលើមានចំនួនពីរ ហោប៉ៅខាងក្រោមមានចំនួនពីរ (ហោប៉ៅស្បោង) ជីបមាត់ចាបចំកណ្តាល តួហោប៉ៅមូល ហោប៉ៅទាំងបួនមានគំរបបញ្ឆិតសន្ទះអណ្តាតចោះរន្ធដាក់ឡេវបង្កប់ ហោប៉ៅអាវខាងលើដាក់ឡេវចំនួនមួយគ្រាប់ ហោប៉ៅអាវខាងក្រោមដាក់ឡេវចំនួនពីរគ្រាប់ពណ៌ដូចអាវ អាវដៃបំពង់ ចុងដៃអាវមានប៉ូលដាក់ឡេវចំនួនពីរគ្រាប់ ។

-ខោ : ចង្កេះលាត ជីបក្បាលជង្គង់ នៅសងខាងចង្កេះខោមានខ្សែរឹត ។ ខោមានហោប៉ៅចំនួនប្រាំមួយ ហោប៉ៅខាងក្រោយមានចំនួនពីរ ហោប៉ៅកាត់ គំរបបញ្ឆិត សន្ទះអណ្តាតចោះរន្ធដាក់ឡេវមួយគ្រាប់ ហោប៉ៅចំហៀងសងខាងមានចំនួនពីរ (ហោប៉ៅបញ្ឆិត) ហោប៉ៅជង្គង់មានចំនួនពីរ (ហោប៉ៅស្បោង) មានជីបផ្នត់ពីរ តួហោប៉ៅជ្រុង គំរបបញ្ឆិតមានសន្ទះអណ្តាត ចោះរន្ធដាក់ឡេវចំនួនពីរគ្រាប់ ឡេវពណ៌ដូចខោ ចុងជើងខោមានខ្សែចង ។

- ពាក់មួកប៉េរ៉េតពណ៌ខ្មៅ ដាក់រូបព្រះសង្ហារប្រភេទ ៣ នៅចំហៀងខាងឆ្វេងមួក ។

- ពាក់ខ្សែក្រវាត់តូចពណ៌ខ្មៅ ដូចឯកសណ្ឋានការងារលេខ ៥ ។
- ខ្សែក្រវាត់ធំ "សាំងទ្បឺរ៉ុង" ពណ៌បៃតងចាស់ ក្រវាត់ពីក្រៅអាវ ។
- ពាក់ស្បែកជើងកវែងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ហើយជើងខោបញ្ចូលក្នុងកស្បែកជើង ។

ខ- ឯកសណ្ឋានថ្នាក់វរសេនីយ៍ : មាន ៧ ប្រភេទ :

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានរបស់ថ្នាក់ឧត្តមសេនីយ៍ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនដូចខាងក្រោម :

ខ/១- ប៉ាន់ឆ្នូតពីរពណ៌បៃតង នៃខោឯកសណ្ឋានធំលេខ ១ ប៉ាន់នីមួយៗមានទទឹងតែប្រវែង ០១ ស.ម ។

ខ/២- ចំពោះមួកកាស្កេត គឺនៅលើជើងមុខមួកមានខ្សែស្ទូចាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាបីធ្នុង និងនៅលើគែមក្បាំងមួកមានក្បាច់ភ្ញីទេសពណ៌មាស ដែលមានចុងឃ្លាតពីជើងមួកទាំងសងខាងចំងាយប្រវែង ០៤ ស.ម ។

គ- ឯកសណ្ឋានថ្នាក់អនុសេនីយ៍ :

គ/១- ឯកសណ្ឋានរបស់ថ្នាក់អនុសេនីយ៍មាន ៤ ប្រភេទគឺ :

ឯកសណ្ឋានធំលេខ ២ ឯកសណ្ឋានការងារលេខ ៥ លេខ ៦ និងលេខ ៧ ។

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានថ្នាក់វរសេនីយ៍ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនដូចខាងក្រោម :

គ/២- មួកកាស្កេត នៅលើជើងមុខមួក មានខ្សែស្ទូចាសភ្លោះពណ៌មាស វេញបញ្ចូលគ្នាបីធ្នុង និងនៅលើគែមក្បាំងមួក មានខ្សែស្ទូចាសភ្លោះពណ៌មាសមួយខ្សែ ។

ឃ- ឯកសណ្ឋាននាយនគរបាលរង :

ឃ/១- ឯកសណ្ឋានរបស់នាយនគរបាលរងមាន ៣ ប្រភេទគឺ :

ឯកសណ្ឋានការងារលេខ ៥ លេខ ៦ និងលេខ ៧ ។

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានថ្នាក់អនុសេនីយ៍ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនដូចខាងក្រោម :

ឃ/២- មួកកាស្កេតថ្នាក់ព្រិន្ទបាល នៅលើជើងមុខមួកមានខ្សែស្បែកប៉ៃតមួយបន្ទះពណ៌មាស មានទទឹងប្រវែង ១៥ ម.ម ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសចំនួនពីរគ្រាប់ ក្បាំងមួកពណ៌ខៀវចាស់ហោត និងដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ១ លើមុខមួក ។

ឃ/៣- មួកកាស្កេតថ្នាក់ពលបាល ដូចមួកថ្នាក់ព្រិន្ទបាលដែរ ប៉ុន្តែនៅលើជើងមុខមួកមានខ្សែស្បែកប៉ៃតមួយបន្ទះពណ៌ប្រាក់ មានទទឹងប្រវែង ១៥ម.ម ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសចំនួនពីរគ្រាប់ ។

នាយនគរបាលរង នៅពេលចូលរួមក្នុងពិធីបុណ្យផ្សេងៗ និងទទួលភ្ញៀវត្រូវស្លៀក ពាក់ឯកសណ្ឋានការងារលេខ ៦ ពាក់ក្រវាត់កពណ៌ខៀវចាស់ ឃ្នាបក្រវាត់ក រូបសញ្ញានគរបាលជាតិប្រភេទ ៤ ពណ៌មាសនៅចំកណ្តាល ។

មាត្រា ២ ._ ឯកសណ្ឋាននគរបាលនារី :

ក- ឯកសណ្ឋាននគរបាលនារីមាន ៤ ប្រភេទគឺ ឯកសណ្ឋានធំលេខ ២ ឯកសណ្ឋានការងារលេខ ៤ លេខ ៥ និងលេខ ៦ ។

ឯកសណ្ឋាននគរបាលនារីស្រដៀងឯកសណ្ឋាននគរបាលបុរសដែរ ប៉ុន្តែមានចំណុចមួយចំនួនខុសគ្នាដូចខាងក្រោម :

១-ឯកសណ្ឋានធំលេខ ២ (វ៉ារីពណ៌ខៀវចាស់) :

-អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី ។

-សំពត់ : ដឹមីស្វារ៉េ ត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយមានឆែក ។

-ពាក់មួកសំបុកពណ៌ខៀវចាស់ ។

-ស្បែកជើងកខ្ចីពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ ។

២-ឯកសណ្ឋានការងារលេខ ៤ (សាហ្វារីវ៉ែន) :

-អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី ។

សំពត់ : ដឹមីស្វារ៉េ ត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់ និងខាងក្រោយឆែក ឬខោ ។

-ពាក់មួកសំបុកពណ៌ខៀវចាស់ ។

-ស្បែកជើង និងស្រោមជើងដូចឯកសណ្ឋានធំលេខ ២ ។

៣-ឯកសណ្ឋានការងារលេខ ៥ និងលេខ ៦ រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចបុរសដែរ ប៉ុន្តែស្លៀកពាក់ជាមួយសំពត់ ឬខោក៏បាន ។

-ពាក់មួកសំបុក ឬ ហ្សិកកីពណ៌ខៀវចាស់ ។

ខ-មួកសំបុកនគរបាលនារីមានរូបភាពដូចខាងក្រោម :

១-មួកសំបុកនគរបាលនារីថ្នាក់វរសេនីយ៍ : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ និងនៅជើងមុខមួកមានខ្សែស្មួតាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាបីធ្លុងមួយខ្សែ ។

២-មួកស៊ុបុកនគរបាលនារីថ្នាក់អនុសេនីយ៍ : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាស ប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសយស៍ប៉ែតពណ៌មាសមួយបន្ទះ ។

៣-មួកស៊ុបុកនគរបាលនារីថ្នាក់ព្រិន្ទបាល : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាស ប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសយស៍ប៉ែតពណ៌ប្រាក់មួយបន្ទះ ។

៤-មួកស៊ុបុកនគរបាលនារីថ្នាក់ពលបាល : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាស ប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសប៉ែតពណ៌ខ្មៅមួយបន្ទះ ។

មាត្រា ៣ ._ ឯកសណ្ឋានរបស់នគរបាលកងកិត្តិយស នគរបាលសណ្តាប់ធ្នាប់ នគរបាលចរាចរ នគរបាលទេសចរណ៍ នគរបាលតំរួតបទបញ្ជា នគរបាលព្រំដែនគោក នគរបាលអន្តរាគមន៍ នគរបាលអង្គរក្ស និងផ្លាកសញ្ញារបស់អង្គភាពនគរបាលជំនាញផ្សេងៗទៀត ត្រូវកំណត់តាមប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៤ ._ រូបព្រះសង្ហារ និងផ្លាកសញ្ញានគរបាលជាតិកម្ពុជាត្រូវបានរៀបចំដូចខាងក្រោម :

ក- រូបព្រះសង្ហារ : មាន ៣ ប្រភេទគឺ :

១-រូបព្រះសង្ហារប្រភេទ ១ : ពណ៌មាសសំរាប់ដាក់លើមុខមួកកាស្កេ ។ រូបព្រះសង្ហារប្រភេទនេះមានទំហំកំពស់ ៧៨ ម.ម និងទទឹង ៧១ ម.ម ។

២-រូបព្រះសង្ហារប្រភេទ ២ : ពណ៌មាសសំរាប់ដាក់លើមុខមួកបៀ្រកគី និងមួកស៊ុបុកនគរបាលនារី ។ រូបព្រះសង្ហារប្រភេទនេះមានទំហំកំពស់ ៥៣ ម.ម និងទទឹង ៥៤ ម.ម ។

៣-រូបព្រះសង្ហារប្រភេទ ៣ : ពណ៌ក្រហម ផ្ទៃពណ៌ស ពីមព័ទ្ធជុំវិញពណ៌មាស និងមានរូបកំរងកួរស្រូវពណ៌មាសអមលំអព្រះរូបព្រះសង្ហាររាងជាស្នែងក្របី សំរាប់ដាក់លើចំហៀងឬកបេរ៉េគីផ្នែកខាងឆ្វេង ។ រូបព្រះសង្ហារប្រភេទនេះមានទំហំកំពស់ ៥៥ ម.ម និងទទឹង ៥៥ ម.ម ។

ខ-ផ្លាកសញ្ញានគរបាលជាតិកម្ពុជា : មាន ៥ ប្រភេទគឺ :

១-ផ្លាកសញ្ញាប្រភេទ ១ : សំរាប់ពាក់បណ្តោកនៅខ្សែរហោជៅអាវខាងស្តាំ ។

ផ្លាកសញ្ញាប្រភេទនេះ ធ្វើរាងជាមេដាយ ដែលមានស្បែកបណ្តោកប្រវែង ១០០ ម.ម បាតស្រួចពណ៌ខៀវចាស់ ។ នៅលើស្បែកបណ្តោកមានផ្លាកសញ្ញារាងមូល អង្កត់ផ្ចិត ៤៩ ប.ម ផ្ទៃពណ៌ខៀវចាស់ នៅចំកណ្តាលផ្ទៃមានរូបរាជសីហ៍ពណ៌មាស ពន្លឺពណ៌ប្រាក់ នៅខាងក្រោមរូបរាជសីហ៍ មានអក្សរមូលសរសេរកាត់ "ន ប ជ ក" ពណ៌ប្រាក់ ហើយមានរូបកងចក្រពណ៌ប្រាក់ភ្លឺមានកាំចំនួន ២១ ព័ទ្ធជុំវិញ ។

២-ផ្លាកសញ្ញាប្រភេទ ២ : សំរាប់ដាក់លើដៃអាវខាងស្តាំចុះពីថ្នេរស្មាចំងាយ ៧៥ ម.ម ។

ផ្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់រាងមូល ផ្ទៃពណ៌ទង់ជាតិ មានអង្កត់ផ្ចិតប្រវែង ៧៧ ម.ម រឹមព័ទ្ធជុំវិញពណ៌ស ទទឹង ០២ ម.ម នៅខាងលើមួយភាគបួន មានផ្ទៃពណ៌ខៀវដែលមានអក្សរមូលពណ៌ស សរសេរកាត់ថា "ន ប" អក្សរកំពស់ ១២ ម.ម ។ នៅផ្នែកខាងក្រោម លើផ្ទៃពណ៌ខៀវមានអក្សរឡាតាំងសរសេរថា " POLICE " អក្សរកំពស់ ១០ ម.ម នៅចំកណ្ដាលលើផ្ទៃពណ៌ក្រហម មានរូបប្រាសាទកំពូលបីពណ៌ស ប្រាសាទមានទំហំកំពស់ ២២ ម.ម បាតប្រវែង ៣៤ ម.ម ។

៣-ផ្លាកសញ្ញាប្រភេទ ៣ : សំរាប់ដាក់លើដៃអាវខាងឆ្វេងចុះពីថ្នេរស្មាចំងាយ ៥០ ម.ម ។

ផ្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់រាងកោង ផ្ទៃពណ៌ទង់ជាតិ ទំហំបណ្ដោយខាងលើប្រវែង ១០៥ ម.ម បណ្ដោយខាងក្រោមប្រវែង ៧០ ម.ម និងទទឹងប្រវែង ២៥ ម.ម មានរឹមព័ទ្ធជុំវិញពណ៌ស ទទឹងប្រវែង ១.៥ ម.ម ហើយនៅចំកណ្ដាលផ្ទៃពណ៌ក្រហម មានអក្សរមូលពណ៌ស សរសេរថា "នគរបាលជាតិកម្ពុជា" អក្សរកំពស់ ៨ ម.ម ។

៤-ផ្លាកសញ្ញាប្រភេទ ៤ : សំរាប់ពាក់នៅលើចុងកអាវទាំងសងខាង នៃឯកសណ្ឋានលេខ ២.៣.៤.៥. និងលេខ ៦ ដោយឡែកឯកសណ្ឋានការងារលេខ ៧ ផ្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់ប៉ាក់សំរាប់ពាក់លើចុងកអាវខាងស្ដាំ ។ ចំពោះថ្នាក់ឧត្ដមសេនីយ៍ និងវរសេនីយ៍ត្រូវប្រើផ្លាកសញ្ញា ប្រភេទនេះពណ៌មាស រីឯថ្នាក់អនុសេនីយ៍ទោះត្រូវប្រើផ្លាកសញ្ញាប្រភេទនេះពណ៌ប្រាក់ភ្លឺ ។

ផ្លាកសញ្ញាប្រភេទនេះ មានរាងមូល អង្កត់ផ្ចិត ២៥ ម.ម ដែលមានរូបជើងពានទ្រគម្ពីរធម្មនុញ្ញ និងនៅខាងលើមានរូបព្រះខ័នពីរខ្វែងគ្នា ហើយមានរូបកម្រងស្លឹកជ្រៃក្រឹមអមលើអទ្រជារាងស្នែងក្របី ដែលមានទងបំបែកចេញពីរូបផ្កាដកចន្ទន៍ ។

៥- ផ្លាកសញ្ញាប្រភេទ ៥ : សំរាប់ដាក់ភ្ជាប់កាបូបអត្តសញ្ញាណប័ណ្ណនគរបាលជាតិ ។

ផ្លាកសញ្ញាប្រភេទនេះ មានរាងមូល អង្កត់ផ្ចិត ៥៤ ម.ម ផ្ទៃពណ៌ខៀវចាស់ រឹមព័ទ្ធជុំវិញពណ៌មាស នៅចំកណ្ដាលមានរូបរាជសីហ៍ពណ៌មាស ពន្លឺពណ៌ប្រាក់ នៅខាងក្រោមរូបរាជសីហ៍មានអក្សរមូលសរសេរកាត់ថា "ន ប ជ ក" ពណ៌ប្រាក់ ដែលមានរូបកងចក្រពណ៌ប្រាក់ មានកាំ ២១ ព័ទ្ធជុំវិញហើយនៅផ្នែកខាងក្រោមកងចក្រ មានបដាសរសេរអក្សរ ឡាតាំងថា " POLICE NATIONALE " ពណ៌ខៀវចាស់ ។

មាត្រា ៥ ._ ទង់នគរបាលជាតិកម្ពុជា :

ទង់នគរបាលជាតិកម្ពុជា មានផ្ទៃពណ៌ខៀវ នៅចំកណ្តាលផ្ទៃទង់មានរូបសញ្ញានគរបាលជាតិប្រភេទ ១ ដែលមានអក្សរមូលពណ៌មាសសរសេរថា : "ក្រសួងមហាផ្ទៃ" នៅខាងលើរូបរាជសីហ៍ និងនៅខាងក្រោម មានអក្សរមូលពណ៌មាសសរសេរថា : "នគរបាលជាតិកម្ពុជា" ។

មាត្រា ៦ ._ ផ្លាកពេញ្ញ និងអត្តលេខរបស់នគរបាលជាតិកម្ពុជា ត្រូវកំណត់តាមប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៧ ._ រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១១៨ អនក្រ.តត

## ស្តីពីការដូរឈ្មោះឃុំ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយសិរីវឌ្ឍនការ៉ង** ជូនមន្ត្រី ០៣ រូប នៃមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែងដែលមានស្នាដៃក្នុងការកសាង និងលើកស្ទួយព្រះពុទ្ធសាសនា ជាពិសេសការចូលរួមកសាងពុទ្ធិកវិទ្យាល័យ ព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :

១- លោក **នុម ហឿន** អនុប្រធានមន្ទីរធម្មការ និងសាសនា

២- លោក **មុំ ចន្ទនារា** អនុប្រធានមន្ទីរធម្មការ និងសាសនា

៣- លោក **ចាន់ ម៉ន** ប្រធានការិយាល័យធម្មការនិងសាសនា ខេត្តព្រៃវែង

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ១១៩ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងអប់រំ យុវជន និង កីឡា
- សារាចរណែនាំលេខ ១០ សរណន ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលស្តីពីនីតិវិធី នៃការតែងតាំងមន្ត្រីរាជការស៊ីវិល
- យោងតាមសំណើ របស់ក្រសួងអប់រំ យុជន និង កីឡា

- យោងលិខិតលេខ ៥៧ មសរ-គគ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០០ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

**សំរេច**

មាត្រា ១.- តែងតាំងមន្ត្រី ដូចមានរាយនាមខាងក្រោម :

១- លោក ឡេង ឈីវអ៊ាន សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឋានៈស្មើ អគ្គនាយករង

២- លោក ឆ សោ ព្រឹទ្ធបុរស នៃមហាវិទ្យាល័យគរុកោសល្យ ឋានៈស្មើ ប្រធាននាយកដ្ឋាន

៣- លោក ម៉ៅ សុគ្គន នាយកវិទ្យាស្ថានភាសាបរទេស ឋានៈស្មើប្រធាននាយកដ្ឋាន

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលមានការពាក់ព័ន្ធ និង អស់លោកដែលមានរាយនាមក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២[illegible]ា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១២០ អនក្រ .តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សំរេច**

**មាត្រា ១.-** តែងតាំង លោក ស៊ុម ឫទ្ធីសែន ជាប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល នៃក្រសួងយុត្តិធម៌

**មាត្រា ២.-** បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយ និង អនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមី ខ្លួនក្នុងមាត្រា ១ ខាងលើត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ [illegible]**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាស ប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត កំពង់ឆ្នាំង

សំរេច

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនបរទេសចំនួន ០២រូប ដែលបានធ្វើអំណោយជាថវិកាក្នុងការសាងសង់អគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ នៅសាលាបឋមសិក្សាព្រះឡូរ ឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោក អ៊ីស៊ុកា អ៊ីជីរ៉ូ (IZUKA ICHIROU) ទឹកប្រាក់ចំនួន ២០.០០០$US

២- លោក ណាកាមុីរ៉ា សូវ៉ា (NAKAMURA SHOWA) ទឹកប្រាក់ចំនួន ២០.០ ០០$US

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ១២២ អនក្រ.តត**
**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសេ នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

សំរេច

មាត្រា ១.- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរជន ០២ រូប ដែលបានបរិច្ចាគថវិកា ក្នុងការជួយកសាងសមិទ្ធផលសាធារណៈ នៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយនាមខាងក្រោមនេះ

ក- មេដាយមាសស្ថាបនាជាតិ :

- លោក តូស៊ីហ៊ិកូ ហូរីជី (TOSHIHIKO HORIUCHI)
ពាណិជ្ជករស្ថានទូតជប៉ុនប្រចាំកម្ពុជា ជួយកសាងអាគារសិក្សា ០១ ខ្នងមាន ០៦ បន្ទប់នៅសាលាបឋមសិក្សា ច្រេស ឃុំ ច្រេស ស្រុក កំពង់ត្រឡាច
ចំណាយទឹកប្រាក់អស់ចំនួន ២៧.០០០ដុល្លារអាមេរិក ។

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ

- លោក អេន សំអុល ជួយជួសជុលព្រះវិហារ នៅវត្ត ពានី ឃុំ ពានី ស្រុកកំពង់ត្រឡាចចំណាយទឹកប្រាក់អស់ចំនួន ៥.១៣៧ ដុល្លារអាមេរិក ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ឆ្នាំងត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបាន ពេញផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

បណ្ឌិត និងត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ១២៣ អនក្រ .តត**

**ស្តីពីការតម្លើងឋានៈមន្ត្រីរាជការ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១.- ត្រូវបានតម្លើងឋានៈលោក សាមីឌី ស៊ីទឡ្ហានា ជំនួយការសម្តេចនាយករដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយករង ។

មាត្រា ២.- បទបញ្ញត្តិទាំងឡាយ ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១២៤ អនក្រ .តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរអំពីការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**មាត្រា ១.-** ត្រូវបានតែងតាំងអស់លោក ជា **ជំនួយការទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី** មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ដូចមានរាយនាមខាងក្រោម ៖

១- លោក **ហួ មនោ** ជាជំនួយការឯកឧត្តម **ជុំ ភារណាល់** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី

២- លោក **នួន សំណាង** ជាជំនួយការឯកឧត្តម **ឱម យ៉ិនទៀង** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី

**មាត្រា ២-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១២៥ អនក្រ .តត
## ស្តីពីការជូនមេដាយ សុវត្ថារា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការថ្នាក់ដឹកនាំចំនួន១៣ រូបដែលមានស្នាដៃ ល្អប្រសើរ និងគុណបំណាច់ខ្ពស់ក្នុងការដឹកនាំដំណើរការងារនានាៗនៃក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសេនាសុវត្ថារា**

១- ឯកឧត្តម **ខៀវ មុត** អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស

២- លោក **អ៊ុង ហុកលឹម** អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

**ខ-មេដាយអស្សឫទ្ធិសុវត្ថារា**

១- លោក **លី ណារុន** អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

២- លោក **គុជ សាវាន** អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៣- លោក **សែម សារឿន** ប្រធាននាយកដ្ឋាន រដ្ឋបាល-ហិរញ្ញវត្ថុ

៤- លោក **ឈរ ថារណាត** ប្រធាននាយកដ្ឋាន អធិការកិច្ច

៥- លោក **សំ ចំរើន** ប្រធាននាយកដ្ឋាន ផែនការ និង កិច្ចការច្បាប់

៦- លោក **ចាយ សាមិត** ប្រធាននាយកដ្ឋាន ការពារ និង អភិរក្សធម្មជាតិ

៧- លោក **ហេង ណារ៉េត** ប្រធាននាយកដ្ឋាន ត្រួតពិនិត្យការបំពុលបរិស្ថាន

៨- លោក **នុច និមល** អនុប្រធាននាយកដ្ឋាន អប់រំព័ត៌មាន និងផ្សព្វផ្សាយបរិស្ថាន

៩- លោក **ណា ជុម** ប្រធាននាយកដ្ឋាន ពិនិត្យអង្កេតវាយតំលៃហេតុប៉ះពាល់បរិស្ថាន

១០- លោក **ឆាយ យូម** ប្រធានមន្ទីរបរិស្ថាន ខេត្តបាត់ដំបង

១១- លោកស្រី **ដោក សុធា** ប្រធានមន្ទីរបរិស្ថាន ខេត្តកំពង់ឆ្នាំង

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

បាត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២- សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០០

### សេចក្តីសំរេចលេខ ១៧ . សសរ

ស្តីពី ការបង្កើត

គ្រុមពិគ្រោះយោបល់ឈូងសមុទ្រថៃខាងភាគីកម្ពុជា

និងជាគ្រុមពិគ្រោះយោបល់ថ្នាក់ជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

### សំរេច

ប្រការ ១ : បង្កើតក្រុមពិគ្រោះយោបល់ឈូងសមុទ្រថៃខាងភាគីកម្ពុជា ដោយមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាងក្រសួងបរិស្ថាន | ជាប្រធាន |
| - តំណាងក្រសួងការបរទេស | សមាជិក |
| - តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | សមាជិក |
| - តំណាងអាជ្ញាធរជាតិកិច្ចការព្រំដែន | សមាជិក |

- ព័ណៃរាងអាជ្ញាធរប្រេងកាតជាតិកម្ពុជា សមាជិក

ប្រការ ២ : ក្រុមពិគ្រោះយោបល់ឈូងសមុទ្រថៃខាងភាគីកម្ពុជា មានភារកិច្ចចូលរួមពិភាក្សាជាមួយក្រុមអ្នកជំនាញខាងច្បាប់ នៃប្រទេសទាំងបួននៅឈូងសមុទ្រថៃ (កម្ពុជា វៀតណាម ថៃ និងម៉ាឡេស៊ី) ដើម្បីស្វែងរករូបមន្តបង្កើតនូវឥរិយាបថការសហប្រតិបត្តិការថ្នាក់តំបន់មួយ លើការគ្រប់គ្រងការចែករំលែក បទពិសោធន៍ លើវិស័យគ្រប់គ្រងធនធានធម្មជាតិសមុទ្រ រក្សាបរិស្ថានសមុទ្រ នាវាចរណ៍សមុទ្រ នេសាទសមុទ្រ បទពិសោធន៍ក្នុងការអភិវឌ្ឍន៍តំបន់សមុទ្រព្រួតគ្នា និងកិច្ចសហការផ្សេងៗទៀត ដែលមានចែងក្នុងមាត្រា ១២២និង១២៣ នៃអនុសញ្ញាច្បាប់សមុទ្រ UNCLOS 1982 ។

ប្រការ ៣ : ក្រុមពិគ្រោះយោបល់ឈូងសមុទ្រថៃខាងភាគីកម្ពុជា មានតួនាទីបន្ថែមជាក្រុមពិគ្រោះយោបល់ថ្នាក់ជាតិ "National Consultative Group" ដែលមានភារកិច្ចអនុវត្តការងារជាអ្នកសម្របសម្រួលកិច្ចការផ្សេងៗរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទិននិងកិច្ចសហការ ឈូងសមុទ្រថៃ ។

ប្រការ ៤ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងបរិស្ថាន ក្រសួងការបរទេស ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង អាជ្ញាធរជាតិកិច្ចការព្រំដែនត្រូវអនុវត្ត សេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្ណាក្រសួង

## សេចក្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០០

## ប្រកាស

### ប្រកាសលេខ ២១៣ មល.ប្រក

### ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ

### របស់នាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម

***

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតីស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល
- បានឃើញការចាំបាច់របស់ក្រសួង

### សំរេច

**ប្រការ ១.-** នាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម ជាអង្គភាពសេនាធិការ ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានឧស្សាហកម្ម ទទួលបន្ទុកដឹកនាំ គ្រប់គ្រង និង អភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្មនៅទូទាំង ប្រទេស ហើយមានតួនាទីរ៉ាប់រងនូវភារកិច្ចដូចតទៅ :

- រៀបចំផែនការរយៈពេលខ្លី មធ្យម វែង និង ផែនការមេស្របតាមនយោបាយរបស់រាជរដ្ឋាភិបាល និងអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម

- ជំរុញលើក ទឹកចិត្ត តំរង់ទិស និងគាំទ្រឧស្សាហកម្មតូច-សិប្បកម្ម អនុវត្តច្បាប់ គោលនយោបាយនានា នៃវិស័យឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំច្បាប់ បទបញ្ញា លិខិតបទដ្ឋាននានា រួមទាំងផ្នែកហិរញ្ញវត្ថុ និង សារពើពន្ធ ដែលពាក់ព័ន្ធ និងការងារឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំ និង អនុវត្តគោលការណ៍ សហប្រតិបត្តិការជាមួយបណ្តាប្រទេស ស្ថាប័ន អង្គការជាតិ និង អន្តរជាតិនានា ដើម្បីជំរុញអភិវឌ្ឍន៍ឧស្សាហកម្មតូច-សិប្បកម្ម
- ពិនិត្យវាយតំលៃ និងអនុម័តបើកគំរោងវិនិយោគឯកជន ដោយផ្ទាល់ ឬដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- រៀបចំគំរោង និងសំរបសំរួលគំរោងវិនិយោគសាធារណៈ និងពិនិត្យតាមដានការអនុវត្តន៍គំរោងនេះ
- រៀបចំប្រកាសអនុញ្ញាតឲ្យឧស្សាហកម្មតូច-សិប្បកម្ម ដំណើរការ
- វាយតំលៃលើយថាប្រភេទ និងបរិមាណវត្ថុធាតុដើមប្រើប្រាស់របស់ឧស្សាហកម្មតូច-សិប្បកម្មតាមដាន បទដ្ឋានបច្ចេកទេស និង តាមដានការប្រើប្រាស់
- រៀបចំបញ្ជីផលិតផលឧស្សាហកម្មតូច-សិប្បកម្ម
- ផ្តល់លិខិតបញ្ជាក់នានា ដែលពាក់ព័ន្ធដល់ផលិតកម្មរបស់ឧស្សាហកម្មតូច-សិប្បកម្ម
- ប្រមូលផ្តុំទិន្នន័យ និងវិភាគវាយតំលៃលទ្ធផលអនុវត្តរបស់ឧស្សាហកម្មតូច-សិប្បកម្ម ដែលបែកចេញជា១០ផ្នែកគឺ :

  ១- ផ្នែកស្បៀងម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់
  ២- ផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់ និង ផលិតផលអំពីស្បែក
  ៣- ផ្នែកផលិតផលអំពីឈើ អនុផលព្រៃឈើ
  ៤- ផ្នែកផលិតផលក្រដាស
  ៥- ផ្នែកគីមី ផលិតផលពីកៅស៊ូ ផ្លាស្ទិក
  ៦- ផ្នែកផលិតផលពីរ៉ែ មិនមែនលោហៈ
  ៧- ផ្នែកឧស្សាហកម្ម លោហៈមូលដ្ឋាន
  ៨- ផ្នែកឧស្សាហកម្ម កែច្នៃលោហៈ
  ៩- ផ្នែកឧស្សាហកម្ម ផ្សេងៗ
  ១០- សិប្បកម្មប្រពៃណី

- សិក្សាអំពីច្បាប់ គោលនយោបាយបទដ្ឋាននានា របស់ជាតិ និង អន្តរជាតិ ស្តីពីការគ្រប់គ្រងស្តារ និង អភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំ តាក់តែងច្បាប់ គោលនយោបាយគ្រប់គ្រង និង លើកទឹកចិត្តផលវិស័យឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំគ្រប់គ្រង ផ្សព្វផ្សាយ និង អភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំបទបញ្ញា លិខិតបទដ្ឋាននានា សេចក្តីណែនាំផ្សេងៗ ដែលពាក់ព័ន្ធនិងវិស័យឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំបណ្តុះបណ្តាលអំពីការងារគ្រប់គ្រង និងការងារអភិវឌ្ឍន៍ឧស្សាហកម្មតូច-សិប្បកម្ម ដល់ឧស្សាហករ និង សិប្បករ តាមខេត្ត-ក្រុង
- គ្រប់គ្រង ត្រួតពិនិត្យ សកម្មភាពផលិតកម្ម សេវាកម្ម នៃមូលដ្ឋានឧស្សាហកម្មតូច-សិប្បកម្មគ្រប់ប្រភេទ
- ជំរុញការិយាល័យចំណុះនីមួយៗ អនុវត្តការងារតាមតួនាទី និង ភារកិច្ចឲ្យបានល្អប្រសើរជាប្រចាំ
- តាមដានត្រួតពិនិត្យរាល់សកម្មភាព អនុវត្តការងារ របស់ការិយាល័យនីមួយៗ និង លើកជាសំណូមពរ រកទិសដៅ ដោះស្រាយចំពោះការលំបាកនានា

**មាត្រា ២.-** នាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម ដឹកនាំដោយប្រធានមួយរូប និង អមដោយអនុប្រធានមួយចំនួន ជាជំនួយការ តាមការចាំបាច់។

**ប្រការ៣.** នាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម មានរចនាសម្ព័ន្ធដូចតទៅ ៖

- ការិយាល័យ រដ្ឋបាល
- ការិយាល័យអភិវឌ្ឍន៍
- ការិយាល័យឧស្សាហកម្មតូច
- ការិយាល័យសិប្បកម្ម

**ប្រការ ៤.-** តួនាទី និង ភារកិច្ចជាគោល របស់ការិយាល័យនីមួយៗ ៖

**១- ការិយាល័យរដ្ឋបាល**

**តួនាទី ៖**

ការិយាល័យ រដ្ឋបាល ជាសេនាធិការផ្ទាល់ ជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារ ស្ថិតិឧស្សាហកម្មតូច-សិប្បកម្ម និង ការងាររដ្ឋបាល។

**ភារកិច្ច :**

- លើកគំរោងថវិកាឃរដ្ឋបាល ប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំ តំកល់ឯកសាររបស់នាយកដ្ឋាន (ច្បាប់ អនុក្រឹត្យ គោលនយោបាយ និង លិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធ នៅក្នុងនាយកដ្ឋាន )
- គ្រប់គ្រងចលនៈ និង អចលនៈទ្រព្យ នៅក្នុងនាយកដ្ឋាន
- អង្កេត ប្រមូលទិន្នន័យសរុប និង វិភាគវាយតំលៃលទ្ធផលអនុវត្តការងាររបស់ នាយកដ្ឋាន លើវិស័យឧស្សាហកម្មតូច-សិប្បកម្ម
- ធ្វើរបាយការណ៍បូកសរុបការងារ ប្រចាំខែ ត្រីមាស ឆមាស ៩ខែដើមឆ្នាំ របស់នាយកដ្ឋាន ជូនក្រសួង ។

២-ការិយាល័យអភិវឌ្ឍន៍ :

**តួនាទី :**

ការិយាល័យអភិវឌ្ឍន៍ ជាសេនាធិការផ្ទាល់ ជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម និង បង្កើនកិច្ចសហប្រតិបត្តិការយ៉ាង ជិតស្និទ្ធ ជាមួយអង្គការជាតិ និង អន្តរជាតិ ព្រមទាំងបណ្តាប្រទេសនានាលើពិភពលោក ក្នុងទិសដៅធ្វើ ឲ្យមានការរីកចំរើនលើ វិស័យឧស្សាហកម្មតូច-សិប្បកម្ម។

**ភារកិច្ច :**

- រៀបចំគោលនយោបាយគ្រប់គ្រងឧស្សាហកម្មតូច-សិប្បកម្ម
- ធ្វើផែនការអភិវឌ្ឍន៍រយៈពេល វែង មធ្យម និង ខ្លី សមស្របតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាល និង ទិសដៅរបស់ក្រសួង ក្នុងកម្មវិធីអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម
- លើកគំរោងវិនិយោគសាធារណៈ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម និង តាមដានការអនុវត្តន៍គំរោង
- លើកគោលនយោបាយជំរុញលើកទឹកចិត្ត តំរង់ទិស និងគាំទ្រវិស័យឧស្សាហកម្មតូច-សិប្បកម្ម
- រៀបចំច្បាប់ បទបញ្ជា លិខិតបទដ្ឋាននានា រួមទាំងផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធដែល ពាក់ព័ន្ធ នឹងការអភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច-សិប្បកម្ម
- ពិគ្រោះ និង ផ្តល់យោបល់ ដល់ឧស្សាហកម្មតូច-សិប្បកម្ម ដើម្បីបង្កើនការគ្រប់គ្រង ផលិតកម្ម ឲ្យបានរីកចំរើន

- បើកវគ្គបណ្តុះបណ្តាល ចុះធ្វើការបណ្តុះបណ្តាល និង ផ្តល់យោបល់ដល់ផលិតករ និងសិប្បករ តាមមូលដ្ឋានផលិតកម្មសេវាកម្ម គ្រប់ខេត្ត-ក្រុង
- កសាង និង អនុវត្តគំរោង សហប្រតិបត្តិការជាមួយបណ្តាប្រទេស និង អង្គការអន្តរជាតិនានា ដើម្បីកិច្ចអភិវឌ្ឍន៍ឧស្សាហកម្មតូច-សិប្បកម្ម ។

**៣-ការិយាល័យឧស្សាហកម្មតូច៖**

**តួនាទី :**

ការិយាល័យឧស្សាហកម្មតូច ជាសេនាធិការផ្ទាល់ ជំនួយការឲ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារតាក់តែង (ចងក្រង) ប្រកាស និង លិខិតបញ្ជាក់ផលិតផលនៃមូលដ្ឋានផលិតកម្មសេវាកម្ម វាយតំលៃគំរោងវិនិយោគ និងពង្រឹងការងារ គ្រប់គ្រងមូលដ្ឋានផលិតកម្ម ឧស្សាហកម្មតូចឲ្យបានល្អប្រសើរ ។

**ភារកិច្ច**

- ជំរុញម្ចាស់ឧស្សាហកម្មតូច ឲ្យអនុវត្តច្បាប់របស់ក្រសួង និង រាជរដ្ឋាភិបា
- រៀបចំឯកសារចេញប្រកាស បង្កើតឧស្សាហកម្មតូច
- ពិនិត្យ និង វាយតំលៃគំរោងវិនិយោគឯកជន ផ្នែកឧស្សាហកម្មតូច
- ចេញលិខិតបញ្ជាក់ផលិតផល នៃឧស្សាហកម្មតូច
- រៀបចំបញ្ជីផលិតផល របស់ ឧស្សាហកម្មតូច
- ដោះស្រាយរាល់បាតុភាព របស់បណ្តាមូលដ្ឋានឧស្សាហកម្មតូច ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ និង មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត-ក្រុង
- បើកវគ្គ និង ចុះពង្រឹងការងារគ្រប់គ្រងឧស្សាហកម្មតូច គ្រប់ខេត្ត-ក្រុង។

**៤-ការិយាល័យសិប្បកម្ម :**

**តួនាទី :**

ការិយាល័យសិប្បកម្ម ជាសេនាធិការផ្ទាល់ ជំនួយការអោយថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារ តាក់តែង (ចងក្រង) ប្រកាស និង លិខិតបញ្ជាក់ផលិតផលនៃមូលដ្ឋាន សេវាកម្ម វាយតំលៃគំរោងវិនិយោគ និងពង្រឹងការគ្រប់គ្រងមូលដ្ឋានផលិតកម្ម សិប្បកម្ម ឲ្យបានល្អប្រសើរ ព្រមទាំងស្រាវជ្រាវ រៀបចំ ផ្សព្វផ្សាយ ឯកសារស្តីពីផលិតផលរបស់ សិប្បកម្ម ។

**ភារកិច្ច :**

- ជំរុញម្ចាស់សិប្បកម្មឲ្យអនុវត្តច្បាប់របស់ក្រសួង និង រាជរដ្ឋាភិបាល
- រៀបចំឯកសារចេញប្រកាស បង្កើតសិប្បកម្ម
- ពិនិត្យ និង វាយតំលៃគំរោងវិនិយោគឯកជន ផ្នែកសិប្បកម្ម

- ចេញលិខិតបញ្ជាក់ផលិតផលរបស់សិប្បកម្ម
- រៀបចំបញ្ជីផលិតផលរបស់សិប្បកម្ម
- ដោះស្រាយរាល់បញ្ហាផ្សេងៗ របស់មូលដ្ឋានសិប្បកម្មដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ និង មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្ត-ក្រុង
- បើកគំរោង និង ចុះពង្រឹងការងារគ្រប់គ្រង ណែនាំបច្ចេកទេស ផ្ដល់យោបល់ដល់សិប្បករដើម្បីបង្កើនគុណភាព គ្រប់គ្រងមូលដ្ឋានផលិតកម្ម ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងលើកកំពស់វប្បធម៌ជាតិ
- ស្រាវជ្រាវ ចងក្រងឯកសារ ពត៌មាន-ស្ថិតិ ស្ដីពីសិប្បកម្ម ប្រពៃណី
- ផ្សព្វផ្សាយអំពីផលិតផលសិប្បកម្ម ប្រពៃណី ។

ប្រការ ៥ : បទបញ្ញត្តិ និង សេចក្ដីសម្រេចទាំងឡាយណា ដែលមានន័យផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ ទុកជានិរាករណ៍ ។

ប្រការ ៦ : អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្ម អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន បុគ្គលិក និង ប្រធាននាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌសមត្ថកិច្ច រៀងៗខ្លួន តាមប្រកាសនេះ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

តារាងឧបសម្ព័ន្ធទី ១ នៃប្រកាសលេខ : ២១៣ បណ.ប្រក
ចុះថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០០

## អង្គការលេខ នាយកដ្ឋានឧស្សាហកម្មតូច-សិប្បកម្ម




★★★